01030524

E314/5/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 10 / 2014
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញលើ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C * C.E.T.C *

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីមេធាវីការពារក្តី ខៀវ សំផន សុំឱ្យពិចារណាឡើងវិញលើ "ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២" របស់អង្គជំនុំជម្រះ ("ដីកាកំណត់កាលបរិច្ឆេទ") ។ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យពន្យារការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ រហូតដល់ក្រោយពេលខ្លួនបានដាក់សារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ រួចរាល់ និងសុំឱ្យពន្យារពេលចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២/០២ រហូតដល់ពេលមានសេចក្តីសម្រេចទៅលើសំណើសុំនេះជាមុនសិន (ឯកសារ E314/5/1)។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ដោយផ្អែកលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនរបស់ខ្លួន (ឯកសារ E314/5/1 *កថាខណ្ឌ ៣, ២៦ និងទំព័រ ១១*)។ សហព្រះរាជអាជ្ញាបានដាក់សារណាឆ្លើយតបប្រឆាំងនឹងសំណើនេះ កាលពីថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ (E314/5/2)។

២. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកថា ការពិចារណាឡើងវិញមិនមែនជាផ្នែកមួយនៃក្របខណ្ឌគតិយុត្តិ នៅ អ.វ.ត.ក ឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាឡើងវិញលើសំណើសុំតែក្នុងករណីមាន "សំណើជាថ្មីដែលមានភស្តុតាងថ្មី ឬកាលៈទេសៈថ្មី" តែប៉ុណ្ណោះ (ឯកសារ E282/2/1/2 កថាខណ្ឌ ៣, ឯកសារ E299/2 កថាខណ្ឌ ៥, ឯកសារ E238/11/1 កថាខណ្ឌ ៧-៨, ឯកសារ E292/2/1 កថាខណ្ឌ ៤)។

៣. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះបានពិចារណា និងបានបដិសេធរួចហើយទៅលើសំណើពីមុនស្រដៀងៗគ្នានេះរបស់មេធាវីការពារក្តី ខៀវ សំផន សុំឲ្យពន្យារកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ (ឯកសារ E314/5, ឯកសារ E301/5/5/1)។ មេធាវីការពារក្តីមិនបានបង្ហាញអំពីអត្ថិភាពនៃកាលៈទេសៈ ឬភស្តុតាងថ្មី ដែលអាចផ្តល់យុត្តិកម្មដល់សំណើសុំថ្មីនេះឡើយ។ ទទ្បីករណ៍របស់មេធាវីការពារក្តីដែលថា មេធាវីការពារក្តីមិនអាចសរសេរសារណាបណ្តឹងសាទុក្ខរបស់ខ្លួនបានក្នុងខណៈដែលកំពុងចូលរួមក្នុងសំណុំរឿង ០០២/០២ ដោយសារតែពុំមានធនធានគ្រប់គ្រាន់ (ដោយសំដៅទៅទទ្បីករណ៍ពាក់ព័ន្ធនឹងសមភាពរវាងគូភាគីនៅក្នុងរឿងក្តី) ត្រូវបានលើកឡើងរួចហើយនៅក្នុងសវនាការបឋមបន្ថែម (ឯកសារ E1/240.1 ទំព័រ ៣៩) ហើយត្រូវបានអង្គជំនុំជម្រះពិចារណារួចរាល់ហើយដែរ នៅពេលអង្គជំនុំជម្រះចេញដីកាកំណត់កាលបរិច្ឆេទសវនាការ។ អង្គជំនុំ-ជម្រះរម្លឹកថា ដីកាកំណត់កាលបរិច្ឆេទគឺជាឧបករណ៍សម្រាប់រៀបចំសវនាការ ដូច្នេះហើយមិនតម្រូវឲ្យមានហេតុផលលម្អិតឡើយ។ មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ចាប់តាំងពីខែ មីនា ឆ្នាំ ២០១៤ មក ខៀវ សំផន បានចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួនពីរដង ដែលបង្ហាញអំពីការប្រែប្រួលកាលៈទេសៈផ្សេងៗ។ អង្គជំនុំជម្រះកត់សម្គាល់ថា ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យទាំងពីរដងនេះមានរយៈពេលខ្លី ហើយរហូតមកដល់ពេលនេះ ជនជាប់ចោទបានជាសះស្បើយពេញលេញ ហើយអង្គជំនុំជម្រះយល់ឃើញថា ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យនេះមិនប៉ះពាល់ដល់សេចក្តីសន្និដ្ឋាននៃរបាយការណ៍វេជ្ជសាស្ត្រពីមុនឡើយ។ ហេតុនេះ ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យទាំងពីរដងនេះ មិនបង្កើតបានជាកាលៈទេសៈថ្មីឡើយ។

៤. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំខាងលើរបស់មេធាវីការពារក្តី ខៀវ សំផន។